អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ប្រទេសកម្ពុជារំពឹងថា ការនាំចេញផ្លែស្វាយស្រស់ទៅកាន់ទីផ្សារប្រទេសចិនអាចឈានដល់បរិមាណ ១០ម៉ឺនតោន
- ប្រទេសកម្ពុជាត្រៀមរៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយឆ្ពោះទៅមុខ ប្រសិនបើឯកសិទ្ធិពាណិជ្ជកម្មត្រូវបានបាត់បង់
- តារាងប្រៀបធៀបតម្លៃផលិតផលនាំចេញ ប្រចាំខែកុម្ភៈ ឆ្នាំ២០២១
- ប្រធានាធិបតីកូរ៉េខាងត្បូង លោក Moon Jae-in ប្តេជ្ញាបង្កើនការចំណាយសារពើពន្ធ ដើម្បីបង្កើតការងារ
- ធនាគារកណ្តាលហ្វីលីពីនរំពឹងថា នឹងរក្សាអត្រាការប្រាក់ទាបបំផុតដើម្បីគាំទ្រដល់សេដ្ឋកិច្ច
- ក្រសួងរតនាគារនៃសហរដ្ឋអាមេរិកផ្តល់អំណាចយ៉ាងច្រើនដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការសម្រេចចិត្តលើការប្រើប្រាស់ថវិកានៃជំនួយសង្គ្រោះកូវីដ-១៩
- តម្លៃប្រេងកើនឡើង បន្ទាប់ពីបណ្តាញបំពង់បង្ហូរប្រេងមេរបស់សហរដ្ឋអាមេរិកទទួលរងការវាយប្រហារ តាមប្រព័ន្ធកុំព្យូទ័រ

ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

ចងក្រង និងបូកសរុបដោយ

- ធីម ប៊ុនធឿន ប្រធានការិយាល័យវិភាគចំណូល-ចំណាយ

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ប្រទេសកម្ពុជារំពឹងថាការនាំចេញផ្លែស្វាយស្រស់ទៅកាន់ទីផ្សារប្រទេសចិនអាចឈានដល់បរិមាណ១០ម៉ឺនតោន



*ប្រភព៖khmertimes, 2021 រូបភាព៖ KT/Pann Rachana*

យោងតាមការបង្ហាញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រទេសកម្ពុជាបានកំណត់គោលដៅក្នុងការនាំចេញនូវផ្លែស្វាយស្រស់ចំនួន១០ម៉ឺនតោនក្នុងមួយឆ្នាំៗទៅកាន់ប្រទេសចិន ដែលជាប្រទេសមានសេដ្ឋកិច្ចធំលំដាប់ទី២ នៅលើពិភពលោក បន្ទាប់ពីមានការនាំចេញជាលើកដំបូងកាលពីពេលថ្មីៗនេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើរតួជាកម្លាំងជំរុញយ៉ាងសំខាន់ក្នុងការនាំចេញនេះ តាមរយៈការជំរុញផ្នែកដាំដុះ ឧបករណ៍វេចខ្ចប់ឱ្យមានលក្ខណៈស្តង់ដារ ដើម្បីឆ្លើយតបនឹងតម្រូវការនៅក្នុងទីផ្សារដ៏ធំរបស់ចិនឱ្យបានយ៉ាងតិច ១០ម៉ឺនតោន ក្នុងមួយឆ្នាំ ដោយផ្អែកលើទិន្នផលផ្លែស្វាយនៅកម្ពុជាមានចំនួនប្រហែល ១,៦លានតោន ក្នុងមួយឆ្នាំ។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន (GACC) បានដាក់ពិន្ទុទទួលស្គាល់ជាផ្លូវការនូវចំការស្វាយចំនួន ៣៧ និងរោងចក្រវេចខ្ចប់ចំនួន ៥ ដែលបានចុះបញ្ជីសម្រាប់នាំចេញផ្លែស្វាយស្រស់ទៅកាន់ប្រទេសចិន។ ការដឹកជញ្ជូនលើកដំបូងគឺត្រូវបានធ្វើការនាំចេញដោយក្រុមហ៊ុនដែលទទួលស្គាល់ទាំង ៥ និងបរិមាណនៃការនាំចេញមានចំនួន ១០០តោន។ ផ្លែស្វាយស្រស់របស់កម្ពុជា គឺជាផ្លែឈើស្រស់ទី២ បន្ទាប់ពីផ្លែចេកដែលអាចនាំចេញទៅប្រទេសចិនដោយផ្ទាល់។

ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានបញ្ជាក់បន្ថែមថា នេះជាសមិទ្ធផលប្រកបដោយផ្លែផ្កាមួយផ្សេងទៀតតាមរយៈកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន។ យោងតាមទិន្នន័យពីគេហទំព័រ globalprice.info តម្លៃលក់រាយធម្មតានៃផ្លែស្វាយស្រស់នៅក្នុងប្រទេសចិន គឺ១,៣ដុល្លារក្នុងមួយគីឡូក្រាម។ ឯកអគ្គរដ្ឋទូតចិនប្រចាំនៅកម្ពុជាបានមានប្រសាសន៍ថា ការនាំចេញផ្លែស្វាយស្រស់នេះ គឺអាចឆ្លុះបញ្ចាំងពីកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយរវាងប្រទេសទាំងពីរលើគ្រប់វិស័យ ជាពិសេសក្នុងវិស័យ

កសិកម្មមានភាពវិជ្ជមាន និងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។

លើសពីនេះ ផ្លែស្វាយស្រស់របស់កម្ពុជាត្រូវបាននាំចេញទៅប្រទេសជិតខាង ដូចជាប្រទេសថៃ និងវៀតណាម ក៏ដូចជាប្រទេសកូរ៉េខាងត្បូង និងសហភាពអឺរ៉ុប។ ក្នុងរយៈពេល៤ខែដើមឆ្នាំនេះ កម្ពុជាបាននាំចេញផ្លែស្វាយស្រស់ចំនួន ១៤ម៉ឺនតោនទៅកាន់ទីផ្សារបរទេសផ្សេងៗ។ ជារួម ប្រទេសកម្ពុជាមានផ្ទៃដីដាំដុះផ្លែស្វាយសរុបចំនួន ១៣០ ០០០ហិកតា ដែលទទួលបានទិន្នផលផ្លែស្វាយស្រស់យ៉ាងហោចណាស់ ១,៦លានតោន ត្រូវបានផលិតជារៀងរាល់រដូវ៕ *ដោយ សេន ចន្នី*

*ប្រភព៖ khmertimes.com, ចេញផ្សាយថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០២១*

## ប្រទេសកម្ពុជាត្រៀមរៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយឆ្ពោះទៅមុខ ប្រសិនបើឯកសិទ្ធិពាណិជ្ជកម្មត្រូវបានបាត់បង់



*ប្រភព៖ khmertimes, 2021*

រាជរដ្ឋាភិបាលកម្ពុជាកំពុងរៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយ ដើម្បីដោះស្រាយបញ្ហាប្រឈមបន្ទាប់ពីការអនុគ្រោះសម្រាប់ការនាំចេញរបស់ខ្លួនត្រូវបានកាត់បន្ថយបន្តិចម្តងៗ និងនៅពេលដែលលំហូរជំនួយមានការថយចុះ នេះបើយោងតាមការលើកឡើងរបស់រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មក្នុងអំឡុងពេលសិក្ខាសាលាស្តីអំពីផលប៉ះពាល់នៃការបញ្ចប់ការអនុគ្រោះដល់ប្រទេសអភិវឌ្ឍន៍តិចតួចនៅក្នុងវិស័យវាយនភ័ណ្ឌ និងសម្លៀកបំពាក់។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយអង្គការពាណិជ្ជកម្មពិភពលោក(WTO) នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ (UN-DESA) អង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ(UNCTAD) និងមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ(ITC) ដោយមានការចូលរួមពី បណ្តាប្រទេសអភិវឌ្ឍន៍តិចតួច រួមមានប្រទេសកម្ពុជា បង់ក្លាដែស ឡាវ និងប្រទេសនេប៉ាល់។

ថ្លែងនៅក្នុងសិក្ខាសាលានេះ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មក៏បានលើកឡើងអំពីសារៈសំខាន់នៃវិស័យកាត់ដេរក្នុងការជំរុញកំណើនសេដ្ឋកិច្ចរបស់កម្ពុជា និងអត្ថប្រយោជន៍ នៃការអនុគ្រោះពន្ធសម្រាប់កំណើននៃការនាំចេញរបស់កម្ពុជា។ លោកបានបន្តថា ផលប៉ះពាល់នៃការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួច គឺអាចមានបញ្ហាប្រឈមលើការអនុគ្រោះពន្ធពាណិជ្ជកម្ម ភាពទាក់ទាញសម្រាប់ការវិនិយោគ និងភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងវិស័យកាត់ដេរ សម្លៀកបំពាក់ និងឱកាសសម្រាប់ទទួលជំនួយពាណិជ្ជកម្ម។ ដូចនេះ

ដើម្បីជំនះបញ្ហាប្រឈមនានាបន្ទាប់ពីការបាត់បង់ឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច (Least-Developed Country) ក្រសួងបានត្រៀមលក្ខណៈរួចជាស្រេចតាមរយៈការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ ដែលអាចធ្វើឱ្យប្រទេសកម្ពុជា ពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់ខ្លួន និងត្រៀមខ្លួនសម្រាប់ការចាកចេញប្រកបដោយជោគជ័យពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច។ ការត្រៀមលក្ខណៈរួមមាន ការធ្វើពិពិធកម្មទីផ្សារនាំចេញតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគី ការជំរុញឱ្យមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ព្រមទាំងការរៀបចំបង្កើតជាគោលនយោបាយ និងយុទ្ធសាស្ត្រពាណិជ្ជកម្មផងដែរ។

ប្រទេសអភិវឌ្ឍន៍តិចតួច គឺជាប្រទេសដែលមានប្រាក់ចំណូលទាប ប្រឈមមុខនឹងឧបសគ្គយ៉ាងធ្ងន់ធ្ងរដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងងាយរងគ្រោះខ្លាំងចំពោះវិបត្តិសេដ្ឋកិច្ច និងបរិស្ថាន ខណៈធនធានមនុស្សនៅមានកម្រិតទាប។ ប្រទេសកម្ពុជាបានធ្វើការផ្លាស់ប្តូរពីប្រទេសមានប្រាក់ចំណូលទាបទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥។ ប៉ុន្តែ ប្រទេសកម្ពុជានៅតែមានស្ថានភាពជាប្រទេសអភិវឌ្ឍន៍តិចតួចដូចដែលបានកំណត់ដោយអង្គការសហប្រជាជាតិ ដែលនេះនឹងអាចឱ្យកម្ពុជារក្សាបាននូវឯកសិទ្ធិពាណិជ្ជកម្មរបស់ខ្លួនសម្រាប់មួយរយៈពេលខាងមុខទៀត។ តាមរយៈការព្យាករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានបង្ហាញថា ប្រទេសកម្ពុជាទំនងជាផ្លាស់ប្តូរស្ថានភាពចេញពីប្រទេសដែលមានការអភិវឌ្ឍតិចតួចនៅឆ្នាំ២០៣០ ប្រសិនបើប្រទេសកម្ពុជាវិលត្រឡប់ទៅរកអត្រាកំណើនដូចមុនពេលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ *ដោយ សេន ចន្ទី*

*ប្រភព៖ khmertimes.com, ចេញផ្សាយថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០២១*

## តារាងប្រចាំសប្តាហ៍៖ តារាងប្រៀបធៀបតម្លៃផលិតផលនាំចេញ ប្រចាំខែកុម្ភៈ ឆ្នាំ២០២១

តារាងខាងក្រោមនេះ បង្ហាញពីការប្រៀបធៀបការនាំចេញផលិតផលគ្រប់ប្រភេទក្នុងខែកុម្ភៈ ឆ្នាំ២០២១ ដែលមានកំណើនប្រហែល ១១% បើធៀបនឹងខែកុម្ភៈ កាលពីឆ្នាំ២០២០។ ការនាំចេញទាំងនោះរួមមាន ៖ សំលៀកបំពាក់ វាយនភ័ណ្ឌ អង្ករ ស្បែកជើង កង់ ផលិតផលកសិកម្ម កាបូបធ្វើដំណើរ និងផលិតផលផ្សេងៗ នេះបើយោងតាមព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ដែលបានចេញផ្សាយកាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ និងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១។

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២១នេះ ការនាំចេញផលិតផលមានការកើនឡើងភាគច្រើនលើគ្រប់មុខទំនិញទាំងអស់ លើកលែងតែទំនិញស្បែកជើង កាបូបធ្វើដំណើរ រួមទាំងសំលៀកបំពាក់ ដែលមានការថយចុះ។ ការនាំចេញវាយនភ័ណ្ឌមានការកើន ៦១% ផលិតផលផ្សេងៗកើន ៧៤% និងអង្ករកើនជិត ៨%។

ដោយឡែក ការនាំចេញស្បែកជើង កាបូបធ្វើដំណើរ និងសំលៀកបំពាក់ គឺថយចុះ ១៩%, ១៥%, ២% រៀងគ្នា

បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ រីឯ កង់ និងផលិតផលកសិកម្មពុំមានសកម្មភាពទេ បើធៀបនឹងរយៈពេលដូចគ្នា។

ទំនិញទាំងអស់ខាងលើនេះ ត្រូវបាននាំចេញទៅទីផ្សារពិភពលោកដែលមានជាអាទិ៍៖ អាស៊ានមានកើនឡើងជិត ៩២% កាណាដាកើន ៣៩% និងប្រទេសដ៏ទៃទៀតកើន ៣៥% ចិនកើន ២១% និងសហរដ្ឋអាមេរិកកើន១០% នេះបើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ចំណែកឯការនាំចេញទៅ សហគមន៍អ៊ឺរ៉ុបបានថយចុះជិត ៤៥% និងទៅជប៉ុន និងកូរ៉េខាងត្បូងថយចុះប្រហែល ១០% ដូចគ្នា បើធៀបនឹងកំឡុងពេលដូចគ្នា។ សរុបជារួមការនាំចេញផលិតផលគ្រប់ប្រភេទទៅកាន់ទីផ្សារពិភពលោកក្នុងខែកុម្ភៈ ឆ្នាំ២០២១នេះ ដែលមានការកើនប្រមាណ ១១% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន៕

**បញ្ជាក់៖ ទិន្នន័យនេះមិនរាប់បញ្ចូលតំបន់សេដ្ឋកិច្ចពិសេសទេ។** *ដោយ ឈន ហាំ*

| ល.រ | ប្រភេទផលិតផល/ទីផ្សារគោលដៅ | ខែកុម្ភៈ ឆ្នាំ ២០២០ | ខែកុម្ភៈ ឆ្នាំ ២០២១ | កំណើន (%) |
|---|---|---|---|---|
| | សរុបរួម | 1,019,924,209.61 | 1,132,880,174.72 | **11.07%** |
| 1 | សំលៀកបំពាក់ | 552,699,915.76 | 540,389,522.43 | -2.23% |
| 2 | ស្បែកជើង | 117,176,954.39 | 94,833,921.48 | -19.07% |
| ៣ | វាយនភ័ណ្ឌ | 6,979,219.44 | 11,258,785.68 | 61.32% |
| 4 | អង្ករ | 44,768,895.68 | 48,248,922.88 | 7.77% |
| 5 | ការបូបធ្វើដំណើរ | 91,315,574.52 | 77,302,141.07 | -15.35% |
| 6 | ផលិតផលកសិកម្ម | 0.00 | 0.00 | គ្មាន |
| 7 | កង់ | 0.00 | 0.00 | គ្មាន |
| 8 | ផលិតផលផ្សេងៗ | 206,983,649.82 | 360,846,881.18 | 74.34% |

| ល.រ | ប្រភេទផលិតផល/ទីផ្សារគោលដៅ | ខែកុម្ភៈ ឆ្នាំ២០២០ | ខែកុម្ភៈ ឆ្នាំ ២០២១ | កំណើន (%) |
|---|---|---|---|---|
| | សរុបរួម | 1,019,924,209.61 | 1,132,880,174.72 | **11.07%** |
| 1 | សហរដ្ឋអាមេរិក | 292,090,011.80 | 321,577,030.72 | 10.10% |
| 2 | កាណាដា | 49,621,525.43 | 69,111,889.03 | 39.28% |
| ៣ | ជប៉ុន | 70,744,458.54 | 64,385,851.28 | -8.99% |
| 4 | សហគមអ៊ឺរ៉ុប | 273,885,609.92 | 151,792,963.76 | -44.58% |
| 5 | អាស៊ាន | 164,224,605.10 | 314,633,618.22 | 91.59% |
| 6 | ចិន | 67,053,199.72 | 81,372,729.22 | 21.36% |
| 7 | កូរ៉េ | 17,976,622.16 | 16,138,175.27 | -10.23% |
| 8 | ប្រទេសដ៏ទៃទៀត | 84,328,176.94 | 113,867,917.22 | 35.03% |

*ប្រភព៖ ក្រសួងពាណិជ្ជកម្មកម្ពុជា នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ និងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១*

# ព័ត៌មាន និងទិន្នន័យរបស់បណ្ដាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## ប្រធានាធិបតីកូរ៉េខាងត្បូង លោក Moon Jae-in ប្ដេជ្ញាបង្កើនការចំណាយសារពើពន្ធដើម្បីបង្កើតការងារ




*ប្រភព៖ CNA ២០១៦, រូបភាព៖ Reuters/Jeon Heon-Kyun, Pool*

រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េខាងត្បូង នឹងបង្កើនការចំណាយសារពើពន្ធក្នុងករណីចាំបាច់ ដើម្បីបង្កើនការងារខណៈដែលប្រទេសនេះប្រឈមនឹងអត្រាគ្មានការងារធ្វើ

ដ៏អាក្រក់បំផុតក្នុងរយៈពេលពីរទសវត្សរ៍ ក្នុងអត្រា៥% ក្នុងរយៈពេលចាប់ពីខែមករា ដល់ ខែមីនា ដោយយោងតាមប្រសាសន៍លោក Moon Jae-in ប្រធានាធិបតីកូរ៉េខាងត្បូង។

ទន្ទឹមនឹងនេះ គោលនយោបាយរបស់លោក នឹងផ្តោតលើការធ្វើឱ្យប្រាកដថា សេដ្ឋកិច្ចនឹងកើនឡើងខ្ពស់ជាង ៤%នៅក្នុងឆ្នាំនេះ ដែលខ្ពស់ជាងការព្យាករណ៍របស់ក្រសួងហិរញ្ញវត្ថុក្នុងចន្លោះពី៣% ទៅ ៤%ប៉ុណ្ណោះ។ គោលនយោបាយសារពើពន្ធនេះ ក៏នឹងយកចិត្តទុកដាក់បន្ថែមទៀតចំពោះយុវជន និងស្ត្រីដែលកំពុងឆ្លងកាត់ការលំបាក តាមរយៈការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការចំណាយថវិកាបន្ថែមប្រសិនបើចាំបាច់ និងអនុវត្តច្បាប់ថវិកាការងារដែលមានស្រាប់ឱ្យបានយ៉ាងឆាប់រហ័ស។

ជាមួយគ្នានេះ វិធីសាស្ត្របង្កើនចំណាយយ៉ាងសកម្មដោយអ្នកធ្វើគោលនយោបាយ បានបង្កើតឱ្យការងើបឡើងវិញនូវតម្រូវការក្នុងស្រុក មានកម្រិតមធ្យម ហើយរដ្ឋាភិបាលបានសន្យាថានឹងចំណាយថវិកាចំនួន ៣១០ទ្រីលានវ៉ុន ស្មើនឹង ២៧៥ ប៊ីលានដុល្លារ តាមរយៈថវិកាបន្ថែមចំនួន ៤ នៅក្នុងឆ្នាំ២០២០៕

*ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន channelnewsasia.com, ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១*

## ធនាគារកណ្តាលហ្វីលីពីនរំពឹងថា នឹងរក្សាអត្រាការប្រាក់ទាបបំផុតដើម្បីគាំទ្រដល់សេដ្ឋកិច្ច




*ប្រភព៖ CNA ២០២០, រូបភាព៖ REUTERS/Romeo Ranoco*

ធនាគារកណ្តាលហ្វីលីពីនត្រូវបានគេរំពឹងថា នឹងរក្សាអត្រាការប្រាក់គោលរបស់ខ្លួននៅកម្រិតទាបមួយ នៅថ្ងៃព្រហស្បតិ៍ (ទី០៦ ឧសភា) បន្ទាប់ពីសេដ្ឋកិច្ចទំនងជាបានធ្លាក់ចុះក្នុងរយៈពេល៥ត្រីមាសជាប់ៗគ្នា គិតត្រឹមកំលុងពេលពីខែមករា ដល់ខែមីនា។ សេដ្ឋវិទូទាំង ១៣ នាក់ បានព្យាករណ៍ថា Bangko Sentral ng Pilipinas (ធនាគារកណ្តាលហ្វីលីពីន BSP) នឹងរក្សាអត្រាការប្រាក់របស់ខ្លួននៅអត្រា ២,០% នៅក្នុងកិច្ចប្រជុំលើកទី៤ ខាងមុខនេះ។

កិច្ចប្រជុំរបស់ធនាគារកណ្តាល នឹងធ្វើឡើងនាថ្ងៃអង្គារ ដែលត្រូវបានគេរំពឹងថា នឹងបង្ហាញពីកំណើនផលិតផលក្នុងស្រុកសរុប(ផ.ស.ស.) បានធ្លាក់ចុះ៣% នៅក្នុងត្រីមាសទី១ ធៀបនឹងមួយឆ្នាំមុន ទោះបីជាបានងើបឡើងពីការធ្លាក់ចុះរហូតដល់ ៨,៣% កាលពីត្រីមាសមុននេះ។ ការធ្លាក់ចុះនេះបណ្តាលមកពីតំបន់រដ្ឋធានី

ដែលរួមមានទីក្រុងចំនួន១៦ និងមានប្រជាជនយ៉ាងតិច ១៣លាននាក់ ដែលរួមចំណែកក្នុងប្រមាណ ៤០% នៃ ផ.ស.ស.របស់ប្រទេស ត្រូវបានរឹតបន្តឹងឡើងវិញ ដោយសារការកើនឡើងនូវករណីឆ្លងវីរុសកូវីដ-១៩ ដែលបានចាប់ផ្តើមកាលពីខែមីនា។

សេដ្ឋវិទូមួយចំនួនរំពឹងថា BSP នឹងរក្សាអត្រាដដែល រហូតដល់ចុងឆ្នាំ២០២១ ទោះបីជាអតិផរណាកើនលើស គោលដៅពី ២% ទៅ ៤% ដែលមូលហេតុចម្បងគឺ ដោយសារការផ្គត់ផ្គង់សាច់ជ្រូកមិនបានគ្រប់គ្រាន់។ ជាមួយគ្នានេះ BSP បានប្តេជ្ញាបន្តគាំទ្រដល់សេដ្ឋកិច្ច ដែលបានធ្លាក់ចុះដល់កម្រិត ៩,៦% កាលពីឆ្នាំមុន ដោយសារការបិទខ្ទប់ ខណៈពេលដែលសេដ្ឋកិច្ច ត្រូវបានគេព្យាករណ៍ថា នឹងស្ទុះងើបឡើងវិញនៅឆ្នាំនេះ។ ទោះបីជាយ៉ាងណា អ្នកសេដ្ឋកិច្ចមួយចំនួនបានលើកឡើងថា ការស្ទុះងើបឡើងវិញអាចនឹងខកចិត្ត ដោយការចាក់វ៉ាក់សាំងមានការយឺតយាវ បន្ថែមពីលើការព្រួយបារម្ភអំពីកំណើនសេដ្ឋកិច្ចប្រទេសនេះ៕

*ដោយ វត្តា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន channelnewsasia.com ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### ក្រសួងរតនាគារនៃសហរដ្ឋអាមេរិកផ្តល់អំណាចយ៉ាងច្រើនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការសម្រេចចិត្តលើការប្រើប្រាស់ថវិកានៃជំនួយសង្គ្រោះកូវីដ-១៩



*ប្រភព៖ CNBC ២០២១, រូបភាព៖ Jonathan Ernst/Reuters*

យោងតាមក្រសួងរតនាគារ នៃសហរដ្ឋអាមេរិកបានឱ្យដឹងថា បណ្តារដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន មានសេរីភាពក្នុងការសម្រេចចិត្តលើការប្រើប្រាស់ថវិកាសរុបចំនួន៣៥០ ប៊ីលានដុល្លារអាមេរិក នៃថវិកាជំនួយសង្គ្រោះកូវីដ-១៩ ដែលជាថវិកានៃគម្រោងផែនការជួយសង្គ្រោះប្រជាជនអាមេរិក (American Rescue Plan) របស់លោកប្រធានាធិបតី Joe Biden។

ថវិកាដែលនឹងបែងចែកទៅរដ្ឋបាលនីមួយៗ គឺខុសគ្នា ហើយក្នុងរយៈពេលប៉ុន្មានថ្ងៃ និងសប្តាហ៍ខាងមុខនេះ ការិយាល័យកម្មវិធីនៃការស្តារឡើងវិញរបស់ក្រសួងរតនាគារ នឹងធ្វើការដោយផ្ទាល់ជាមួយអភិបាលរដ្ឋ អភិបាលក្រុង សមាជិក-សមាជិកាសភា និងមន្ត្រី

មូលដ្ឋាន ដើម្បីឆ្លើយសំណួរ និងធានាថា ថវិកានឹងផ្តល់ជូនទៅឱ្យសហគមន៍បានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

ក្នុងថវិកាសរុបចំនួន ៣៥០ប៊ីលានដុល្លារអាមេរិក បណ្តារដ្ឋ និងរដ្ឋធានីវ៉ាស៊ីនតោន នឹងទទួលបានថវិកាចំនួន ១៩៥,៣ប៊ីលានដុល្លារអាមេរិក ខណៈរដ្ឋបាលថ្នាក់តំបន់ (Counties) នឹងទទួលបានថវិកាចំនួន ៦៥,១ប៊ីលានដុល្លារអាមេរិក។ ចំណែកឯរដ្ឋបាលថ្នាក់ក្រុង (Cities) និងរដ្ឋបាលកុលសម្ព័ន្ធ (tribal and territories) នឹងទទួលបានថវិកាចំនួន ៤៥,៦ប៊ីលានដុល្លារអាមេរិក និង ២៤,៥ប៊ីលានដុល្លារអាមេរិក រៀងគ្នា។

ថវិកាដែលបានអនុម័តនេះ នឹងប្រើប្រាស់សម្រាប់ចំណាយរួមមាន៖ ការគាំទ្រលើការចំណាយសុខភាពសាធារណៈ ការដោះស្រាយលើផលប៉ះពាល់អវិជ្ជមានចំពោះសេដ្ឋកិច្ចដោយសារតែការរាតត្បាតនៃជំងឺកូវីដ-១៩ ការជួយជួសលើការខាតបង់ចំណូលនៃវិស័យសាធារណៈ ឬការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទឹក បណ្តាញ លូ និងហេដ្ឋារចនាសម្ព័ន្ធធំៗ។

បន្ថែមពីនេះ រដ្ឋបាលនីមួយៗ នឹងទទួលបានថវិការបស់ពួកគេចំនួនមួយលើក ឬពីរលើក អាស្រ័យទៅតាមអត្រានិកម្មភាពរបស់ពួកគេរៀងៗខ្លួន។

ក្រសួងរតនាគារ បានបញ្ជាក់ផងដែរថា រដ្ឋបាលនីមួយៗត្រូវចំណាយនូវថវិកាទាំងនោះ ដើម្បីបំពេញនូវតម្រូវការនៃការឆ្លើយតបទៅនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ និងកសាងឡើងវិញនូវសេដ្ឋកិច្ចដ៏រឹងមាំ និងសមធម៌ ប៉ុន្តែ រដ្ឋបាលនៃបណ្តារដ្ឋ និងតំបន់នីមួយៗ មិនត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់ថវិកាទាំងនោះ សម្រាប់ការបំពេញជំនួសចំណូលពន្ធដែលបានកាត់បន្ថយ ឬសម្រាប់មូលនិធិសោធននិវត្តន៍ទេ។

ទោះជាយ៉ាងណា ការអនុម័តនូវការប្រើប្រាស់ថវិកានេះគឺមានលក្ខណៈទូលំទូលាយ និងអាចបត់បែនបាន៕

*ដោយ ស៊ិន សុភាព៌*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNBC, ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០២១*

## តម្លៃប្រេងកើនឡើង បន្ទាប់ពីបណ្តាញបំពង់បង្ហូរប្រេងមេរបស់សហរដ្ឋអាមេរិក ទទួលរងការវាយប្រហារតាមប្រព័ន្ធកុំព្យូទ័រ




*ប្រភព៖ CNBC ២០២១, រូបភាព៖ Luke Sharrett|Bloomberg|Getty Images*

តម្លៃប្រេង បានកើនឡើងនៅថ្ងៃចន្ទ (ទី១០ ឧសភា) សប្តាហ៍នេះ បន្ទាប់ពីក្រុមហ៊ុនបំពង់បង្ហូរប្រេងដ៏ធំ

របស់សហរដ្ឋអាមេរិក ឈ្មោះ Colonial Pineline ត្រូវបានបង្ខំឱ្យបិទបណ្ដាញបង្ហូរប្រេងរបស់ខ្លួន ដោយសារទទួលរងការវាយប្រហារតាមប្រព័ន្ធកុំព្យូទ័រ (cyberattack)។ បញ្ហានេះ កំពុងបង្កើនការព្រួយបារម្ភអំពីការរាំងស្ទះដល់ការផ្គត់ផ្គង់ប្រេង និងធ្វើឱ្យថ្លៃប្រេងកើនឡើង។

ជាក់ស្ដែង តម្លៃប្រេងឆៅ Brent របស់អង់គ្លេស បានកើនឡើង ៣១សេន ឬ០,៥% ដល់ ៦៨,៥៩ដុល្លារអាមេរិក ក្នុងមួយបារ៉ែល នៅថ្ងៃចន្ទ ទី១០ ខែឧសភា ឆ្នាំ២០២១ គិតត្រឹមម៉ោង ០៨៖២០នាទីព្រឹក ម៉ោងសកល (GMT)។ ខណៈដែលតម្លៃប្រេងឆៅរបស់សហរដ្ឋអាមេរិក West Texas Intermediate (WTI) បានកើនឡើង ៤៦សេន ឬ០,៧% ដល់ ៦៥,៣៦ដុល្លារអាមេរិក ក្នុងមួយបារ៉ែល។ តម្លៃប្រេងប្រទេសទាំងពីរបានកើនឡើងច្រើនជាង ១% កាលពីសប្ដាហ៍មុន ហើយកំណើនសប្ដាហ៍នេះ គឺជាកំណើនប្រចាំសប្ដាហ៍ទី២ ជាប់គ្នារបស់ខ្លួន។

យោងតាមក្រុមហ៊ុន Colonial Pineline បានឱ្យដឹងថា បំពង់បង្ហូរប្រេងមេរបស់ខ្លួន នៅតែពុំទាន់ដំណើរការឡើងវិញ បន្ទាប់ពីការវាយប្រហារដែលបានបិទប្រព័ន្ធដំណើរការតាំងពីថ្ងៃសុក្រ សប្ដាហ៍មុន។ ប៉ុន្តែ បំពង់បង្ហូរប្រេងតូចៗមួយចំនួន ដែលរត់ឆ្លងកាត់រវាងបណ្ដាញធំ និងចំណុចចែកចាយ បានបើកដំណើរការឡើងវិញហើយឥឡូវនេះ។

យ៉ាងណាមិញ សេតវិមានបានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុន Colonial Pineline ដើម្បីជួយឱ្យក្រុមហ៊ុនដំណើរការឡើងវិញ។ យោងតាមលោកស្រី Gina Raimondo រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកបានមានប្រសាសន៍ថា ការជួសជុលនូវបំពង់បង្ហូរប្រេងរបស់ក្រុមហ៊ុន Colonial Pineline គឺជាការងារអាទិភាពមួយរបស់រដ្ឋបាលលោកប្រធានាធិបតី Joe Biden ហើយរដ្ឋាភិបាលអាមេរិក កំពុងធ្វើការងារនេះ ដើម្បីជៀសវាងការរាំងស្ទះដល់ការផ្គត់ផ្គង់កាន់តែធ្ងន់ធ្ងរ។

សូមបញ្ជាក់ផងដែរថា តម្លៃប្រេងបានកើនឡើង ៣៣% នៅឆ្នាំនេះ ដោយសារការកាត់បន្ថយការផ្គត់ផ្គង់ប្រេងដោយអង្គការនៃប្រទេសនាំចេញប្រេង និងសម្ព័ន្ធមិត្តរបស់ពួកគេ ដែលត្រូវបានគេស្គាល់ថា OPEC+ និងការបន្ធូរបន្ថយវិធានការរឹតត្បិតការធ្វើដំណើរ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅសហរដ្ឋអាមេរិក និងអឺរ៉ុប។

ទោះយ៉ាងនេះក្តី អ្នកវិភាគមួយចំនួនបាននិយាយថា តម្រូវការប្រេង នឹងមិនអាចឈានដល់កម្រិតមុនការរាតត្បាតនៃជំងឺកូវីដ-១៩នោះទេ។ ជាមួយគ្នានេះ យោងតាមក្រុមហ៊ុន Goldman Sachs បានព្យាករណ៍ថា តម្លៃប្រេងឆៅ Brent អាចនឹងកើនឡើងដល់ ៨០ដុល្លារអាមេរិក ក្នុងមួយបារ៉ែល។ ចំណែកឯ តម្លៃប្រេងឆៅ WTI អាចនឹងកើនឡើងដល់ ៧៧ដុល្លារអាមេរិក ក្នុងមួយបារ៉ែល ក្នុងរយៈពេល៦ខែខាងមុខនេះ៕

*ដោយ ស៊ិន សុភាក់*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNBC, ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមានៈសន្ទស្សន៍ថ្លៃផ្ទះនៅប្រទេសចិន ការទិញមូលបត្របរទេសដោយជនជាតិកាណាដា និងអត្រាអតិផរណាស្នូលរបស់ប្រទេសកាណាដា លំហូរមូលធនសុទ្ធ និងការលក់ផ្ទះដែលមានស្រាប់នៅសហរដ្ឋអាមេរិក ផលិតភាពការងាររបស់ចក្រភពអង់គ្លេស ការបម្រែបម្រួលការងារពេញម៉ោង និងសន្ទស្សន៍ថ្លៃប្រាក់ឈ្នួល នៅប្រទេសអូស្ត្រាលី ការបញ្ជាទិញគ្រឿងម៉ាស៊ីនរបស់ប្រទេសជប៉ុន កំណើនប្រាក់កម្ចីធនាគារនៅប្រទេសឥណ្ឌា៕

ខាងក្រោម គឺជាប្រតិទិនដែលនាយកដ្ឋានស្រាវជ្រាវថវិកានឹងបន្តតាមដាននៅសប្តាហ៍ក្រោយៈ

ថ្ងៃចន្ទ ទី១៧ ខែឧសភា ឆ្នាំ២០២១

- សន្ទស្សន៍ថ្លៃផ្ទះនៅប្រទេសចិន ធៀបនឹងឆ្នាំមុន សម្រាប់ខែមេសា
- ការទិញមូលបត្របរទេសដោយជនជាតិកាណាដារបស់ប្រទេសកាណាដា សម្រាប់ខែមីនា

ថ្ងៃអង្គារ ទី១៨ ខែឧសភា ឆ្នាំ២០២១

- លំហូរមូលធនសុទ្ធនៅសហរដ្ឋអាមេរិក សម្រាប់ខែមីនា
- ផលិតភាពការងាររបស់ចក្រភពអង់គ្លេស ធៀបនឹងត្រីមាសមុន សម្រាប់ត្រីមាសទី១

ថ្ងៃពុធ ទី១៩ ខែឧសភា ឆ្នាំ២០២១

- សន្ទស្សន៍ថ្លៃប្រាក់ឈ្នួលនៅប្រទេសអូស្ត្រាលី ធៀបនឹងឆ្នាំមុន សម្រាប់ត្រីមាសទី១
- អត្រាអតិផរណាស្នូលរបស់ប្រទេសកាណាដា ធៀបនឹងឆ្នាំមុន សម្រាប់ខែមេសា

ថ្ងៃព្រហស្បតិ៍ ទី២០ ខែឧសភា ឆ្នាំ២០២១

- ការបញ្ជាទិញគ្រឿងម៉ាស៊ីនរបស់ប្រទេសជប៉ុន ធៀបនឹងខែមុន សម្រាបស់ខែមីនា
- ការបម្រែបម្រួលការងារពេញម៉ោងនៅប្រទេសអូស្ត្រាលី សម្រាប់ខែមេសា

ថ្ងៃសុក្រ ទី២១ ខែឧសភា ឆ្នាំ២០២១

- កំណើនប្រាក់កម្ចីធនាគារនៅប្រទេសឥណ្ឌា ធៀបនឹងឆ្នាំមុន សម្រាប់ថ្ងៃទី០៧ ខែឧសភា
- ការលក់ផ្ទះដែលមានស្រាប់នៅសហរដ្ឋអាមេរិក សម្រាប់ខែមេសា